**វគ្គ រង្វាន់ប្រាក់លាន**

មួយកំផ្លៀងមិនមានស្លាកស្នាមអ្វី ស្មើនឹងក្តីអាម៉ាស់ដែលចុះស្នាមក្នុងថ្ងៃការងារដំបូងនោះទេ។

ពេលនេះ ទោះបានអ្នកម្តាយខំស្អំផង លួងលោមផង ក៏នៅមិនស្មើនឹងសំណើចចំអកគ្មានមេត្តា របស់ពួកម៉ាកកំហូច។

«សប្បាយចិត្តម៉េះអ្ហា ឃើញអញត្រូវគេដេញមកផ្ទះ?»

ពួកម៉ាកសើចក្អាកក្អាយ កំដរកំហឹងបុរសសក្តិបួន។

«សុភាពផស់ឯងហ្នឹងហើយ ឡើងហើមថ្ពាល់! អើ! យកទៅមួយកំផ្លៀងអនុស្សាវរីយ៍! ឈឺអីប៉ុណ្ណឹងៗ?!!»

«ប៉ុណ្ណឹងៗអីឯង? បាត់ការងារអស់អីធ្វើមិនខាន!»

ម្តាយពោលមួយៗ៖

«រកឱកាសទៅជម្រាបលោកតាមសម្រួលទៅកូន! កុំឲ្យមានការយល់ខុស!»

គាត់ក្រោកទៅចង្ក្រានរៀបចំភេសជ្ជៈ។ ឯកមានឆ្លៀតឱនមកខ្សឹប៖

«អើ! ល្អហើយ! អស់អាការងារអង្គរក្សហ្នឹង ឯងមានពេលបានស៊ើបក្តីបាត់មនុស្សហ្នឹងពេញដៃពេញជើង មិនល្អ?»

ចិត្រាតវ៉ាភ្លែត៖

«បានអ៊ីចឹងមានអី! សង្ស័យក្របខ័ណ្ឌនៅក្រសួងក៏យ៉ាប់រក្សាផងមិនដឹង! ស៊យមែន!»

«មិនដល់ថ្នាក់ហ្នឹងឯណាអ្ហី?»

នាយកំពូលHackឃើញចិត្រានៅស្ងៀមទាំងស្រពោនសោកស្តាយ គេរកលេសចុះឡើងក៏និយាយបន្ថែម៖

«យកគុណលាងទោស! ស៊ើបឲ្យបានជោគជ័យទៅ!»

ចិត្រានៅស្ងៀមហើយដៀងភ្នែកគិត។

នាយគិតទៅដល់ករណីរឿងខោអាវក្នុងនិងរ៉ូបសមោសរ....

«អាមាន! អ្នកនាងអមរាជាមិនត្រឹមកុម្ម៉ង់រូបវែងសម្រាប់ពិធីធំដុំទេ ថែមទាំង... ទាំងទិញខោអាវក្នុងមកថ្មីៗទៀត?»

ឯកមានបន្ថែមភ្លាមៈ

«អើ! ម៉េចក៏ជួនប៉ះជួនម៉េះអ្វា?»

«អើ! ឲ្យអញគិតម៉េច? នាងឆ្នាំនាគទៀត ហើយក៏ជាកូនអ្នកមាន! ទោះឥឡូវអញអស់កិច្ចជាអ្នកការពារ តែអញមិនដាច់ចិត្តថា ធ្វើមិនដឹងមិនឮដែរអានេះ!»

«ពីណាឲ្យឯងធ្វើមិនដឹងមិនឮអ្ហះ?»

ចិត្រាងាកមករកមិត្ត ហើយសួរនាំម៉ឺងម៉ាត់៖

«យើងគួរណាត់ឧត្តមសេនីយ៍ឌិត សាម៉ុន រាយការណ៍ជាបន្ទាន់!»

យោបល់មួយនេះនឹកស្មានថានឹងបានមិត្តយល់ស្រប ដឹងអី Hacker ឯកមានឮហើយគ្រវីក្បាលសឹងដាច់ក មាត់ប្រញាប់បដិសេធ៖

«គេព្រមស្តាប់ឯងដែរ? គេព្រមជួបឯងអត់រឿងធំប៉ុណ្ណឹងហើយ?»

ឃើញចិត្រានៅស្ងៀមជ្រប់មុខកើតទុក្ខ ឯកមានបន្តភ្លាម៖

«មិនបាច់ទេ! ធ្វើខ្លួនឯងម៉ងទៅ! ណេះ! គ្នាមានតម្រុយពីរទៀតដែលមិនទាន់បានប្រាប់ឯង!»

ចិត្រាងាកមករកមិត្តហើយពោលរអ៊ូរង៉ូវតាមចិត្តសៅហ្មង៖

«ឯងមិនចាំឆ្នាំក្រោយចាំនិយាយ?»

សក្តិប្អូនឯកមានគំហកវិញ៖

«ឯងមានទុកឱកាសឲ្យយើងនិយាយអត់?»

ចិត្រាសម្លក់ហើយនៅស្ងៀមចាំស្ដាប់ ប៉ុន្ដែឯកមាន មិនប្រញាប់និយាយទេ បែរជាសង្ហើញបញ្ជាក់៖

«សន្យាសិន ថារឿងសំខាន់ទាំងបីនេះ ជាតម្រុយសម្រាប់ពីរនាក់ យើងស៊ើបដោយខ្លួនឯង! អត់ប្រាប់ពីណាទាំងអស់ សូម្បីតែឧត្ដមសេនីយ៍ ឌិត សាម៉ុន!»

ចិត្រាចងចិញ្ចើមតាមសម្លឹងភាពប្រាកដប្រជា លើមុខមិត្ត។ គេលែងសួរចង់ដឹងរឿងពីចំណុចនោះបែរជាមកជជីកសួរ ឯកមានទាំងក្ដីសង្ស័យ៖

«ឯងដូចចម្លែកអាមាន? ម៉េចក៏ឥឡូវដូរចិត្តមកជា អន្ទះសាចង់ស៊ើបម៉េះអ៊្ហា?»

ឯកមានឆ្លើយតបផ្ទួងមិនលាក់លៀម មិនបង្អង់ទុក៖

«លុយ! លុយ! លុយ! មួយ៥រយលានរៀលអានេះ!»

«អ្ហះ?»

ចិត្រាជ្រួញចិញ្ចើមព្រោះមិនយល់ តែឯកមានពន្យល់បន្ថែម៖

«សេដ្ឋីម្នាក់ក្នុងចំណោមសេដ្ឋីទាំងបួនដែលបាត់កូនស្រី ប្រកាសព្រឹកនេះថា អ្នកណាក៏ដោយឲ្យតែមានដំណឹងនាំទៅដល់ការរកឃើញកូនស្រីខ្លួន នឹងបានសារគុណ៥រយលានរៀល!»

ចិត្រាបើកភ្នែកគ្រលួងរាប់ដៃជើង គិតទូរទាត់ចំនួនប្រាក់រង្វាន់។

«ចុះទម្រាំសេដ្ឋីទាំងបួន? លុយឡើងខាប់ដូចអី?»

ឯកមានសួរបន្ដទាំងញញឹមញញៀម ធ្វើឲ្យចិត្រាអេះក្បាលញាប់ស្មេរ ភ្លេចអស់កង្វល់ដោយស្នាមកំផ្លៀង។ នាយសក្ដិបួនឆ្លើយតបទៅកាន់មិត្តទាំងស្មុគចិត្តគិតលុយចុះឡើង៖

«តែ៥រយលានរៀលគិតគុណជាដុល្លារមិនទាន់ចេញផង ទម្រាំបួនដងទៀតអ៊្ហា!»

ឯកមានក្រោកចោលមិត្ត ហើយបែរទៅចាក់ទឹកក្រេបទាំងមាត់រអ៊ូបន្ទោស៖

«ខ្សោយគណិតម៉េះ អាខ្សោយគណិត!»

«លោកស្នងការខលមកកូន!»

សំឡេងអ្នកម្ដាយលាន់មក ធ្វើឲ្យការជជែកត្រូវកាត់ផ្ដាច់យ៉ាងបន្ទាន់ព្រោះម្នាក់ៗខ្លាចការសន្ទនាអម្បាញ់មិញនេះត្រូវបែកធ្លាយ។ ចំណែកស្ត្រីជាម្ដាយវិញ ក្ដីបារម្ភធំធេងជាងគេរបស់គាត់ក្នុងពេលនេះគឺថា តើលោកឱត សាម៉ុនទូរសព្ទមកព្រោះមិនទាន់ដាក់ទោសទណ្ឌ រឿងកាលពីព្រឹកមិញអស់ចិត្ត ឬអ្វី?

ដៃនាយចិត្រាទទួលទូរសព្ទពីអ្នកម្ដាយទាំងទឹកមុខខ្វល់ខ្វាយ ហើយមាត់វាចាបន្ទាន់៖

«សូមគោរពទាន!»

«ចិត្រា ចេញមកជួបខ្ញុំឥឡូវ! មួយទៀត! កុំស្លៀកឯកសណ្ឋាន!»

សំឡេងលោកឧត្ដមសេនីយ៍មិនមានអ្វីលើសពីប៉ុន្មានម៉ាត់នេះ ចុះហេតុអ្វីបានជាធ្វើឲ្យនាយមានអារម្មណ៍ថាគាត់មិនមានកំហឹងមកលើខ្លួន ថែមទាំងមានអ្វីម្យ៉ាងសំខាន់និងបន្ទាន់ត្រូវការពិភាក្សា?

«បាទទាន! ខ្ញុំចេញទៅភ្លាម!»

ចិត្រាស្ទុះក្រោក ចំណែកឯកមាន ចំហមាត់ធ្លុងតាមមើលមិត្ត។ អង្គរក្សកម្សត់ស្រវ៉ារកស្បែកជើង ទាំងមាត់និយាយសង្កត់នាយHacker ៖

«កុំថាលុយ៥រយលាន! មិនដឹងចេញទៅ ត្រឡប់មកវិញបានប៉ុន្មានកំផ្លៀងផ្ទើងឯងទេអាម៉ាក!»

វគ្គ អ្នកលេងអាគម

ឧត្ដមសេនីយ៍ ឱត សាម៉ុន មិនមែនហៅនាយទៅជួបនៅស្នងការ រឹតតែមិនមែនទៅផ្ទះលោក ប៉ុន្ដែមកផ្ទះហាងកំព្រូកនៃតំបន់ក្រីក្រមួយ។ ក្រៅពីហៅនាយឲ្យចូលទៅកាន់កូនច្រកមួយដ៏ចង្អៀតនិងជ្រៅសន្លឹមពោរពេញទៅដោយក្រុមមនុស្សស្គមស្គាំង និងប្រព្រឹត្តិអបាយមុខ គាត់ថែមទាំងហាមនាយមិនឲ្យប្រាប់ទីតាំងនេះដល់អ្នកណាទាំងអស់។

ច្រកនេះអាចចូលមកម៉ូតូបាន ប៉ុន្ដែចង្អៀតស្មុគស្មាញនិងត្រូវប្រយ័ត្នព្រោះក្មេងក្មាងរត់ប្រលែង

ពាសវាល។ ឆ្ពោះទៅរកគោលដៅបណ្ដើរ ចិត្រាគិតបណ្ដើរ៖

«លោកនាយមិនអាក្រក់ដល់ថ្នាក់ហៅយើងមកឲ្យពួកអ្នកលេងប្រដៅទេដឹង?»

គេគិតផង ក្រឡេកឆ្វេងស្តាំព្រោះចត់មាត់នឹងក្តីកង្វល់នេះផង។ មិនយូរប៉ុន្មាន នាយអង្គរក្សរកឃើញមេកោយខ្លួនកំពុងស្លៀកស៊ីវិលមើលសឹងមិនចំណាំ។

ឧត្តមសេនីយ៍ដែលប្រើអាវយឺតពត្លក់និងខោរលង់ កំពុងអង្គុយផឹកកាហ្វេវៀតណាម ឯកូនតុតូចកំប៉ិកជាមួយអ្នកណាផ្សេងម្នាក់ដែលចិត្រាមិនធ្លាប់ស្គាល់ពីមុនមកសោះ។

«ចូលមកចិត្រា!»

គាត់ហៅក្នុងសំឡេងធម្មតា ពេលនាយអែបម៉ូតូមកក្បែរ។

រឿងកាលពីព្រឹកនៅតែជាហេតុភេទមិនស្រួលចិត្តប៉ុន្មានឡើយសម្រាប់នាយសក្តិបួន ដូច្នេះហើយគេរកញញឹមក៏មិនចេញ ប៉ុន្តែគេមិនហ៊ានទទឹងនឹងបញ្ជាទេ បានជាដាក់ជន្ទល់ហើយចុះមកបម្រុងគោរព។ លោកឧត្តមសេនីយ៍ រាដៃឃាត់ជាសញ្ញាថា គាត់មិនចង់ឲ្យអ្នកម្តុំនេះស្គាល់ពីសមាសភាពខ្លួនឡើយ។

«អង្គុយចុះមក! មិនបាច់គោរពវែងឆ្ងាយអីទាំងអស់ បើមិនចង់ឲ្យគេដឹងថាយើងជាប៉ូលិស!»

ចិត្រាញញឹមអង្គុយចុះហើយក្រឡេកសម្លឹងបុរសចំណាស់ដែលមានទឹកមុខជ្រីវជ្រួញ។

«នេះគឺអ៊ំពាង!»

គាត់ឈ្មោះពាង ខុសពីរាងកាយស្គមជ្រីវរបស់គាត់។

ចិត្រាគិតអ៊ីចឹងក៏ដោយ តែគេនៅតែរក្សាកិរិយាធម្មតាដោយលើកដៃឡើងសំពះជាការគួរសម។ មិនបង្អង់យូរ ឧត្តមសេនីយ៍ស្រដីបន្ថែម៖

«គាត់ជាអ្នកចេះហោរ! ជាអ្នកច្បាស់ពីផ្លូវងងឹត!»

ចិត្រាចង់ជ្រួញចិញ្ចើមតែគេទប់។ បើមិនបានឮផ្ទាល់ពេលនេះ មិនដឹងឡើយថាឧត្តមសេនីយ៍ដែលមានឈ្មោះល្បីខាងបង្ក្រាបជនក្រៅសង្គមរាប់មិនអស់ មកមានទំនាក់ទំនងអ្វីជាមួយនិងមនុស្សដែលប្រព្រឹត្តិអាគមអូមអាមគួរឲ្យចង់សើច និងមិនគួរយកខ្លួនបៀត។

នាយមិនទាន់បានតបថាយ៉ាងណាផង លោកឧត្តមសេនីយ៍លាន់មាត់បន្ត៖

«តោះ! ឆាប់និយាយតាមអ្វីដែលខ្ញុំសួរអ៊ំមក!»

បុរសស្គម ចាប់ផ្ដើមដៀងភ្នែកសម្លឹងចិត្រាពីលើចុះក្រោម និងពីក្រោមឡើងលើគួរឲ្យទើស ចិត្ត។ សំណាងដែលចិត្រាពុំមែនជាមនុស្សមាត់រអិល ដូច្នេះហើយគេអាចរក្សាភាពស្ងៀម ស្ងាត់អត់ធ្មត់ចិត្តបាន។

«អាក្មេងនេះហាំផុនវា!»

នេះជាពាក្យ៦ម៉ាត់ដំបូងដែលគាត់ស្វាគមន៍មកនាយវរសេនីយ៍ត្រី។

មនុស្សរូបមិនបានហើយ សម្ដីក៏គគ្រាតពេញមួយSetតែម្ដង។ នេះជាអ្វីដែលនាយកំពុងហួស ចិត្ត។រឹតតែកោតទៀតនោះ បុរសនេះដូចជាមិនបានញញើតលោកឱិត សាម៉ុនសោះ ឬមួយ ថាពួកគេធ្លាប់សហការគ្នាពីមុនមក ក៏អាចថាគេមិនដឹងពីសក្តិពិតលើស្មាដែលគាត់បានលាក់ កំបាំងនោះផងមិនដឹង។

«ហេតុអី?»

លោកឱិត សាម៉ុនសួរ បន្តពីការវាយតម្លៃរបស់អ៊ំពាង។

«វាមានតេជៈ វាអាចធ្វើបាន ការពារអ្នកនាងជាឲ្យផុតគ្រោះ!»

ទោះបីបុរសសម្ដីគ្មានទឹកដមកំពុងឲ្យភាពវិជ្ជមានមកឲ្យខ្លួន ក៏វរសេនីយ៍ត្រីនៅតែគ្មាន អារម្មណ៍អ្វីប្រសើរឡើងចំពោះមនុស្សចំណាស់ម្នាក់នេះឡើយ។

«អ្នកនាងមានឆ្នាំរោង កើតកាលឆ្នាំ២០០០ជាឆ្នាំដែលពួកគំនិតអាក្រក់ចង់បានបំផុត ពេល នេះអង្គរក្សម្នាក់នេះមានរាសីល្អអាចការពារគ្រោះឲ្យអ្នកនាងបាន!»

ទ្រាំណាស់ដែរ តែទ្រាំនៅតែមិនបាន ដូច្នេះវរសេនីយ៍ត្រីឌឺគាត់វិញផ្ទួង៖

«ការពារគ្រោះបានល្អ អាចថារងគ្រោះបានល្អ ខ្ញុំស៊ីមួយកំផ្លៀងទាំងព្រឹកណាអ៊ំ!»

អាងថាពេលនេះគ្មានឯកសណ្ឋាន គ្មានឋានន្តរសក្តិជាប់ស្មាទាំងអស់គ្នា ក៏ឌឺលោកឧត្ដម សេនីយ៍មួយប្រាវ និងបញ្ចេញកំហឹងដែលអ៊ំពាងហៅ«វាៗ»ពេញមាត់នោះដែរ។

ដឹងអីលោកអ៊ំពាងមិនខ្វីធ្វើដឹងថាអន្ទិតខឹង។ គាត់បន្ថែមមកទៀត៖

«អាក្រក់មុនល្អក្រោយទេអាអន្ទិត!»

ចិត្រាហួសចិត្ត តែគេនៅស្ងៀមស្ងាត់វិញ។

អ៊ំពាងមិនបានឈប់ទេ គាត់បន្ថែមមកទៀត៖

«មានអន្ទិតនេះជាអង្គរក្សអ្នកនាងមានសុវត្ថិភាព!»

ឧត្តមសេនីយ៍ងៀងភ្នែកមកសម្លឹងភាពទោមនស្សដែលបង្ហាញចេញក្នុងកែវភ្នែកអង្គរក្ស។

ទោះចិត្រាមិននិយាយស្តី តែគាត់ជាអ្នកមានបទពិសោធន៍ចិត្តសាស្ត្រខ្ពស់ដឹងថាត្រូវដោះស្រាយយ៉ាងណាចំពោះ នាយសក្តិបួននេះហើយ។

លោក ឌិត សាម៉ុន ចាប់ផ្តើមចូលប្រធានបទ ដែលជឿថាអាចទាក់ចិត្តកំលោះនេះ៖

«អ៊ំ! ខ្ញុំចង់ដឹងថាអ្នកណាខ្លះអាចជាមុខសញ្ញាចាប់ស្រីៗកូនអ្នកមានឆ្នាំរោងទាំងបួននាក់នោះ?»

«មិនមែន៤នាក់ទេ គឺ៣៥នាក់!»

ចម្លើយរបស់បុរសរូបអាក្រក់ ខ្លីៗ តែមានន័យម្យ៉ាងប៉ះទង្គិចដល់អារម្មណ៍។

ចិត្រាងាកមកសម្លឹងគាត់ ចំណែកគាត់ក៏សម្លឹងគេវិញដូចគ្នា។ បុរសនេះមើលទៅហាក់គ្រោតគ្រាតសម្តី តែកែវភ្នែកហាក់កំពុងប្រាកដប្រជា ចំពោះបទសន្ទនានាពេលនេះណាស់។ វរសេនីយ៍ត្រីបែរមកអានអារម្មណ៍របស់ឧត្តមសេនីយ៍វិញ។ លោកឌិត សាម៉ុន ក៏មើលទៅទំនងជាកំពុងពិចារណាយ៉ាងទោមនស្ស ជាមួយព័ត៌មាននិងតួលេខគួរឲ្យរន្ធត់នេះដែរ។

គាត់ងក់ក្បាលផ្ងក់ៗតែមិនបញ្ចេញការវាយតម្លៃទេ បែរជាដាក់សំណួរវិញខ្សឹបៗ៖

«មានក្មេងស្រី កើតឆ្នាំ២០០០រហូតដល់៣៥នាក់?»

«មនុស្សកើតកាលពីឆ្នាំ២០០០មានជាង២សែននាក់ក្នុងស្រុកខ្មែរលោកប៉ូលិស! រឿងអីរកកូនអ្នកមាន៣៥នាក់មិនជួប???»

តាមពិតឧត្តមសេនីយ៍មិនបានលាក់សមាសភាពពីបុរសនេះសោះ។ ចិត្រាគិតហើយរវើភ្នែកចុះឡើងរំឭកទៅដល់សម្តីរបស់ឯកមាន។

«យើងគួរងាកទៅជ្រុងផ្សេង! សំណួរសំខាន់មិនមែនថាមនុស្សឆ្នាំនាគណាមួយដែលនឹងត្រូវបាត់ខ្លួនបន្តទេ ប៉ុន្តែតើគេយកមនុស្សឆ្នាំនាគទៅណា ហើយទៅធ្វើអី?» កាលណោះឯកមានសួរបកមកវិញ «បើឯងបានជួបអាជនល្មើសហ្នឹង ជួយសួរវា ហើយយកមកប្រាប់គ្នាវិញផង!»។

ចិត្រាងើបមុខសន្សឹមៗសម្លឹងអំពាង ដឹងអីបុរសនេះ ក៏កំពុងសម្លឹងមកគេត្រឡប់វិញដូចគ្នា។ ធម្មតានាយហាក់ចាញ់អំណាចទឹកមុខសោះកក្រោះរបស់គាត់ ហើយនិងកែវភ្នែកមិនក្រែងរអែងចិត្តរបស់គាត់ដែលតែងតែសម្លឹងមក ប៉ុន្តែនាយមិនចង់ឲ្យគាត់បានចិត្ត បានជាប៉ូលិសសក្តិបួនខំផ្តើនសម្លឹងកាត់វិញធ្វើដូចជ្រូកមិនរាទឹកក្តៅ។

ឃើញគេលេងភ្នែក គាត់និយាយប្រាប់ផូង៖

«បើឯងមិនប្រយ័ត្ន អមរាជាអ្នកនាងឯងនឹងទៅតាមលំនាំអ្នកមុនៗ!»

ចិត្រាដាក់ភ្នែកសម្លឹងតុ ដើម្បីទប់ចិត្តដែលជ្រួលមិនច្បាស់កោះត្រើយ។ តែគេទប់ចិត្តថាមិនលបមើលប្រតិកម្មរបស់ឧត្តមសេនីយ៍ក៏មិនកើត។

ពីកន្ទុយភ្នែក គេឃើញលោក ឱត សាម៉ុនទៅជាស្លេក។

គាត់តស៊ូវាយលុកមិនមែនតិចសំណុំរឿងគ្រោះថ្នាក់ទេ ទម្រាំមានឈ្មោះល្បីដល់ពេលនេះ។ ហេតុអីមកដាក់ខ្លួនជឿសម្តីមនុស្សគ្មានឋានៈសង្គមម្នាក់បាន?

ចិត្តមួយនាយប៉ូលិសយល់ថា ទំនងជាកូនស្រីខ្លួនផ្ទាល់បានជាគ្រប់យ៉ាងធ្វើឲ្យលោកឱត សាម៉ុនងាយនឹងបាត់ជំហរ។

ទំនងដែរ អមរាជាជាកូនទោល ស្អាតថ្នាក់នេះហើយ គ្រប់យ៉ាងដូចផ្នួនគ្នាពេកទៀត ជាឪពុកម្នាក់ រឿងអីឲ្យលោកឧត្តមសេនីយ៍មិនក្រពុលមុខ?

វាសនានារីអភិជនទាំងបួននៅមិនទាន់មានចម្លើយ តើឲ្យនាយប៉ូលិសម្នាក់ មិនអន្ទះសាក៏មិនកើត។

ចិត្រានៅស្ងៀមផ្ទៀងស្តាប់វាចាលោកឱត សាម៉ុន ដែលហើបស្រាលៗ៖

«អឺ! វាយកស្រីៗទៅធ្វើអី?»

ភាគទី៧

សំណួរវររសេនីយ៍ត្រីដែលសួរដេញដោលពីមូលហេតុនៅពីក្រោយការចាប់ខ្លួននារីអភិជនមិនបានធ្វើឲ្យអ៊ំពាងភ្ញាក់ផ្អើលអ្វីថែមបន្តិចណាស់។

សកម្មកិរិយារបស់គាត់នៅចំពោះកែវភ្នែកចិត្រាគឺ គាត់និយាយតបមួយៗ ធ្វើដូចធម្មតាៈ

«នៅរាល់២០០០ឆ្នាំម្ដង មនុស្សស្រីពេញវ័យកើតឆ្នាំនេះ ជាមនុស្សដែលពួកអ្នករៀនវិជ្ជាអាគម ជឿថា ពួកគេអាចរួមគ្នាកែប្រែវាសនាអ្នកណាម្នាក់ ឲ្យក្លាយទៅជាអ្នកមានអំណាចផុតកាលបាន! ចំនួន៣៥គឺជាការគុណ៧ដងនៅជ្រុងតូចៗរបស់ពួកផ្កាយ ពួកភូគព្ភសាស្ត្រជឿថានេះគឺជាចំនួនខ្ពស់បង្អស់នៃក្បួនកែប្រែថាមពលរបស់ភពផែនដី!»

«ស្ដាប់មិនយល់!»

ចិត្រានិយាយខ្លី ហើយធ្វើមុខស្មើហាក់មិនយល់ស្រប។

អ៊ំពាងមិនមានប្រតិកម្មខឹងតប តែគាត់ងាកទៅរកអន្តរាគមន៍ពីឧត្តមសេនីយ៍។ កែវភ្នែកគាត់ដូចចង់សួរថា ចង់ឈប់ត្រឹមណេះ ឬចង់ដឹងបន្តទៀត?

លោក ឱត សាម៉ុន  លូកដៃទះស្មាកូនចៅស្រាលៗ ឲ្យនាយទម្លាក់ចោលចិត្តមានះប្រាស់ប្រាល។ បន្ទាប់មក សំឡេងលោកធំលាន់ឡើងស្រាលៗ ទៅកាន់បុរសចំណាស់។

«និយាយទៀតមកអ៊ំ!?»

អ៊ំពាងចាក់ទឹកតែពីប៉ាន់របស់គាត់ ដែលពេលនេះទើបចិត្រាចាប់អារម្មណ៍ថា ក្លិនតែនេះឈ្ងុយមហាឈ្ងុយ។ គាត់មិនមែនចាក់ទឹកដែលមានផ្សែងខ្ជួលនេះសម្រាប់ខ្លួនឯងទេ ប៉ុន្តែគាត់រុញមកឲ្យនាយភ្លក់។

«អ៊ំមិនយកលុយទេ អាក្មេង!»

ចិត្រាសម្លឹងតែដែលមានពណ៌លឿងខ្ចី គួរឲ្យចង់ក្រេប។ ប៉ុន្តែសម្ដីបុរសម្ចាស់ទឹកតែ រឹតគួរឲ្យចង់ស្ដាប់ជាងទៅទៀត។

អ៊ំពាងនិយាយទៅកាន់លោក ឱត សាម៉ុនៈ

«ចង់ដឹងវានោះនៅឯណា ជាអ្នកណា គួរចាប់យកមុំសំខាន់បី! មួយវាមានលុយមានអំណាច មានអ្នកចេះដឹងនៅក្បែរដែលអាចរៀបក្បួនបុរាណដឹងថាមពលមេឃដី ដឹងច្បាស់ក្បួនភូគព្ភ ហើយអាចមានសមត្ថភាពរៀបគម្រោង ចាប់ខ្លួនស្រីប្អូននាក់ស្អាតដូចញែចស្រមោច!»

ឃើញចិត្រានៅគាំងម្រាមដៃលើពែងតែក្តៅនោះ អ៊ំចំណាស់និយាយបន្ត៖

«ទីពីរវាជាភេទប្រុស! មនុស្សស្រីមិនអាចទាញយកថាមពលពីក្បួនដ៏បុរាណនេះជាដាច់ខាត! ដូច្នេះអ្នកនៅពីក្រោយគម្រោងការណ៍ជាមនុស្សប្រុស! ទីបី...»

គាត់បិទភ្នែកហើយជ្រួញចិញ្ចើមពិបាកទ្រាំ ទំនងដូចជាគន់គូរហើយក៏ទំនងដូចជាកំពុងធ្វើមន្ត អាគមដូចក្នុងភាពយន្ត។

ស្ថានភាពគាត់ធ្វើឲ្យអ្នកដែលតាមស្តាប់ទាំងពីរនាក់ដឹងថា មិនហ៊ានទាំងដកដង្ហើមឲ្យឮព្រោះខ្លាចរំខានគាត់។ មិនយូរប៉ុន្មាន គាត់វាចាស្អកៗដោយមិនបើកភ្នែក៖

«ទីបី! មនុស្សនោះត្រូវតែរកទីតាំងដែលខ្ពស់ៗ ទើបអាចបំពេញការស្រូបទាញថាមពលមេឃដីបានហើយទីតាំងនោះមិនអាចមានភាពល្អក់កករ មកប៉ះវាល់រំខានបាន! ភ្នំមួយចំនួនអាចជាកន្លែងដែលសង្ស័យ ប៉ុន្តែទិសពាយ័ព្យនិងខាងជើង គួរតែជាតំបន់សមស្របជាងគេ!»

«បើដូចគាត់និយាយមែន តានេះប្រាកដជាទេវតា ដែលផែនដីបញ្ជូនចុះមកតតាំង និងពួកមនុស្សបាប ប៉ុន្តែបើប៉ូលិសជឿរឿងអស់នេះ មិនបាច់សង្ឃឹមបានសក្តិពាក់បន្ថែមទេ!»

ចិត្រាលបគិតស្ងាត់ៗក្នុងចិត្ត តែមិនហ៊ានវាចាអ្វីរហូតដល់អ៊ំពាងបើកភ្នែកមកវិញ ហើយនាយលើកតែមកក្រេបបន្តប់។

ឧត្តមសេនីយ៍និងបុរសអ្នកជឿអាគម នៅមើលមុខគ្នាចុះឡើងដោយគ្មានវាចាបន្ថែម។ បានបន្តិចគាត់ចាប់ផ្តើមលើកដៃសំពះលា៖

«ខ្ញុំដល់ម៉ោងត្រូវទៅហើយ! តែខ្ញុំនឹងមកជួបអ៊ំទៀត!»

ចិត្រាឃើញបុរសជាអ្នកធំដាក់លុយមួយសំណុំ ក្រដាសពីរម៉ឺនរៀលទៅលើបាតដៃបុរសចំណាស់។ ទំនាក់ទំនងពួកគេ ពុំមែនសមថាទើបតែមានក្នុងពេលនេះឡើយ។

នាយក្រោកទៅរកម៉ូតូ ចំណែកលោក ឱត សាម៉ុន ក៏មកទុំពីក្រោយ បានន័យថាបុរសនេះបានប្រុងប្រយ័ត្នគ្រប់ជំហាន មិនមានឲ្យអ្នកណាម្នាក់ អាចតាមដានដឹងដំណើរការងារមួយនេះដោយងាយឡើយ។

នៅពេលម៉ូតូរត់លើផ្លូវ គាត់ចាប់ផ្ដើមចេញបញ្ជា៖

«ដល់ផ្លូវមុខបត់ស្ដាំទៅ!»

ចិត្រាធ្វើតាមគាត់ ប៉ុន្តែវរសេនីយ៍ត្រី លបមើលតាមកញ្ចក់យាន ឃើញឧត្តមសេនីយ៍ពាក់ម៉ាសបិទបាំងផ្ទៃមុខទុកតែប្រឡោះភ្នែក ហើយថែមទាំងមានពាក់មួកខ្មៅកន្ដឹបទៀត។

នាយដឹងថាប៉ូលិសវ័យចាស់វស្សានេះប្រុងគ្រប់ជំហាន ព្រោះថាជនដៃដល់ប្រាកដជានៅកន្លែងងងឹតតាមដានគ្រប់សកម្មភាពរបស់ប៉ូលិស។

ចិត្រានៅសំងំស្ងៀមហើយបត់ចុះឡើង គ្មានគោលដៅទៅតាមការបញ្ជាប្រាប់របស់គាត់។

ទីបំផុតគេមកដល់ពីមុខគេហដ្ឋានឈើលើក្រោមថ្មមួយដែលចាក់សោពីក្រៅ។

វគ្គ ស្វែងរកយុត្តិធម៌

កូនផ្ទះនេះទំនងជាកម្មសិទ្ធិរបស់គាត់ដែលអាចមកជជែកការសំខាន់ៗ និងជាសម្ងាត់បាន។ វរសេនីយ៍ត្រីដឹងពីមូលហេតុដែលគាត់មកទីនេះ ប៉ុន្តែនៅតែគិតមិនយល់អំពីថាហេតុអ្វីគាត់មិនរើសយកស្នាក់ការប៉ូលិសជាកន្លែងជជែកវិញ។

គាត់បិទទ្វាររបងដោយផ្ទាល់ដៃ ហើយរៀសរវៃពិនិត្យស្ថានភាពជុំវិញផ្ទះប្រកបដោយការប្រុងប្រយ័ត្នល្អិតល្អន់។ អស់ចិត្តអស់ចង់ ឧត្តមសេនីយ៍នាំកូនចៅចូលដល់បន្ទប់ ដែលរៀបចំដូចជាការិយាល័យ មានទាំងតុនិងកៅអី កុំព្យូទ័រ ទូរភេសជ្ជៈ។

«យល់យ៉ាងម៉េចរឿងរបស់អ៊ំពាង!»

ចិត្រាគិតចុះឡើងមិនដាច់ចិត្តឆ្លើយ។ រង់ចាំយូរពេក លោកឧត្តមសេនីយ៍ចាប់ផ្ដើមទៀត៖

«ចិត្រាឯងមិនយល់ថា ស្ដាប់ហេតុផលទៅ គាត់ដូចជាមានចំណុចទំនាក់ទំនងគួរពិចារណាដែរ!»

ចិត្រាអេះអុញ តែនាយមិនអាចស្ងាត់ស្ងៀមតទៅទៀតបាន មានតែប្រឹងរកហេតុផលមកការពារទស្សនៈរបស់ខ្លួនវិញ៖

«ខ្ញុំមិនចេះសោះរឿងភូគព្ភសាស្ត្រ មន្តអាគម ឬថាមពលមេឃដីអីហ្នឹងទេទាន សូម្បីតែធ្លាប់គិតពីរឿងអស់ហ្នឹងម្ដងក៏មិនដែល!»

ឧត្ដមសេនីយ៍ដកដង្ហើមធំ។ គាត់ដៀងភ្នែកតាមដានប៉ូលិសក្រោមបង្គាប់ម្នាក់នេះ ដើម្បីឲ្យដឹងថាតើនាយកំពុងគិតអ្វី ព្រោះលោកដឹងច្បាស់ថាចិត្រាគ្រាន់តែពុំចង់ចេញយោបល់ច្រើនតែប៉ុណ្ណោះ។

ទោះយ៉ាងណាគាត់ដឹងចំណុចខ្សោយខ្លះរបស់នាយ។

គាត់ចាប់ផ្ដើមសួរ៖

«ឯងចង់ចូលរួមជាមួយខ្ញុំបំបែកសំណុំរឿងនេះទេ?»

គេងើបមុខសម្លឹងគាត់យ៉ាងរហ័ស។ តាមថាគាត់មិនសមសួរទេសំណួរមួយនេះ ពីព្រោះគាត់គួរតែដឹងជាស្រេចហើយថា គ្មានកូនប៉ូលិសណាដែលមិនចង់ធ្វើការជាមួយ ឧត្ដមសេនីយ៍ឱិតសាម៉ុនឡើយ។ ធ្វើប៉ូលិសបើមិនរើសយកគាត់ជា Idol ទៅរើសយកអាគាត់កូនប្រសាគាត់?

នឹកឃើញដល់នាយRoy នោះ ចិត្តចង់ឆេវសាជាថ្មី។ សម្ដីមាក់ងាយមិនឲ្យតម្លៃមនុស្សរបស់ជននោះលេចឡើងមកវិញក្នុងអារម្មណ៍វរសេនីយ៍ត្រីយើង «ហាមខ្ជិល! ហាមនិយាយទូរសព្ទ ហាមរវើភ្នែកទៅកន្លែងផ្សេង! ចៅហ្វាយនៅត្រង់ណាត្រូវនៅត្រង់នោះ!» «បាទទាន!» «មិនទាន់ចប់ទេ! ពេលឈរការពារ មិនឲ្យឈរពីមុខ មិនឲ្យនៅពីក្រោយ មិនឲ្យនៅចំហៀងកៀកជាងមួយម៉ែត្រ!»

នាយបញ្ចេញភាពស្រពោនជំនួសចម្លើយ តែឧត្ដមសេនីយ៍ធ្វើមិនដឹងពីអារម្មណ៍បុរសក្មេង។ គាត់និយាយបន្តរដឹក៖

«តែខ្ញុំមានលក្ខខណ្ឌ!»

គេងើបមុខសម្លឹងមក ធ្វើឲ្យឧត្ដមសេនីយ៍ប្រញាប់និយាយបញ្ចប់៖

«ចិត្រា ឯងត្រូវធ្វើជាអ្នកការពារកូនស្រីខ្ញុំបន្តទៀត ហើយតាមឲ្យស្អិតគ្រប់ជំហានចេញចូល!»

គេផ្ទុះចិត្តមានៈនឹកដល់មួយកំផ្លៀងកាលពីព្រឹក ចង់តែតបតថាវិញ រកខុសត្រូវ ប៉ុន្តែនឹកឃើញដល់កំហុសខ្លួនឯង ដែលឆ្លេឆ្លារឿងតម្រុយមិនបានគិតល្អិតល្អន់លើករណីជាក់ស្តែង លុកលុយចូលដល់បន្ទប់កូនស្រីគេ ចំពេលគេងូតទឹក ហើយនៅមិននៅចាប់កាន់ខោអាវក្នុងរបស់គេទៀត។ ពេលនេះមានអីនឹងស្តីរកយុត្តិធម៌កើត នេះបុណ្យហើយដែលគេមិនប្តឹងដកសក្តិ។

«ទាន! ខ្ញុំសុំបកស្រាយរឿងកាលពីព្រឹក!»

គេនិយាយតាមចិត្ត ដែលចង់លាងសម្អាតគ្រប់យ៉ាងឲ្យស្អាតជ្រះនៅនឹងមុខមនុស្សដែលខ្លួនគោរព។ ចំណែកលោកឧត្តមសេនីយ៍ញញឹមលេបទឹកក្រូចទុក ឲ្យនាយចរចា។

«ពីព្រឹកខ្ញុំទទួលដំណឹងមកថា អ្នករងគ្រោះទាំងបួនមុនពេលបាត់ខ្លួន សុទ្ធតែបានកក់កុម្ម៉ង់ខោអាវក្នុងម៉ាកថ្លៃៗ ....»

គេនៅដាច់មួយកំណាត់ត្រឹមណោះ។ គាត់ក៏សើចហើយនិយាយបញ្ចប់ឲ្យ៖

«អ៊ីចឹងហើយឯងក៏ចូលរុករានបន្ទប់កូនស្រីខ្ញុំទាំងព្រហើន រែកញែករករបស់របរដែលអមរាជាបានកុម្ម៉ង់ទិញ កើតរឿងចលាចលពេញផ្ទះ!»

ដោយក្តីអាម៉ាស់ នាយសក្តិបួនជ្រប់មុខ។

« ខ្ញុំព្រមជឿបណ្តោះអាសន្ន! និយាយរឿងដែលចិត្រាឯងដឹងចេញឲ្យអស់ក្នុងពេលនេះមក!»

ឃើញវរសេនីយ៍ត្រីនៅតែបន្តនៅស្ងៀមស្ងាត់ ឧត្តមសេនីយ៍និយាយពន្យល់បន្ថែម៖

«លោកជំទាវបារម្ភកូនស្រី និងរឿងកេរ្តិ៍ឈ្មោះ បានជាប្រាសប្រាល់មិនបានសួរនាំវែងឆ្ងាយនិយាយជ្រុលដល់ពាក្យបណ្តេញ! ខ្ញុំសុំទោសជំនួសភរិយា! ចំណែកខ្ញុំខ្លួនឯងដឹងថានាយជាមនុស្សល្អ តែខ្ញុំចាំនិយាយគ្នាស្ងាត់ៗ មិនទាន់ចង់បើបើកកាយអាថ៌កំបាំងអ្វីនៅមុខមនុស្សម្នា! ពេលនេះគ្មានអ្នកណាទេ ឆាប់និយាយឲ្យអស់មក!»

បុរសនេះមិនត្រឹមមានឋានៈខ្ពង់ខ្ពស់ ថែមទាំងមានការពិចារណាវែងឆ្ងាយ ធ្វើឲ្យនាយសក្តិបួនទន់ចិត្ត ចាប់ផ្តើមរំឭកក្នុងអារម្មណ៍ឡើងវិញ នូវបណ្តាហេតុការណ៍នានាចាប់ពីចំណុចតូចៗរហូតឈានដល់ខ្លួនកើតតក់ក្រហល់វង្វេងវង្វាន់រត់ទម្លុះបន្ទប់កូនស្រីមេដឹកនាំ។

«លោកនាយ! នៅស្នងការធ្លាប់ឮលោក Roy លើកឡើងថា អ្នកនាងពិនណា មុនបាត់ខ្លួន ប្រើសម្លៀកបំពាក់សមោសរ ទោះមិនដឹងថាអ្នកផ្សេងៗទៀតដូចគ្នាដែរអត់ ប៉ុន្តែអ្នកនាងអមរាដាបានទិញឈុតសមោសរមកដែរហាក់ជួនគ្នាពេកហើយ!»

លោកឧត្តមសេនីយ៍ច្រាស់ច្រាល់ គាត់ចាប់ផ្ដើមសង្ស័យទោះជាប្រើសំឡេងទាប៖

«រ៉ូបជប់លៀងហ្អី!? ត្រូវម៉ាច់របាយការណ៍សម្ងាត់នៅក្នុងដៃប៉ូលិស កត់ត្រាចម្លើយពីគ្រួសារអ្នករងគ្រោះទាំងបួនថា គេឃើញពួកនាងចុងក្រោយក្នុងសម្លៀកបំពាក់ រាត្រីសមោសរមានតម្លៃខ្ពស់ដូចៗគ្នា!»

វរសេនីយ៍ត្រីគិតថា ការយល់ឃើញរបស់មេកោយមិនខុសអ្វីពីខ្លួនឡើយ គេចាប់ផ្ដើមនិយាយបន្ថែម៖

«ទាន! បានជាខ្ញុំតក់ក្រហល់ដោយគ្រាន់តែឮអ្នកនាងផានូជ្រុះបែកផើងផ្កា ព្រោះខ្ញុំយល់ថាអ្នកនាង  អមរាដាកំពុងស្ថិតនៅក្នុងរយៈពេលដ៏គ្រោះថ្នាក់! សម្ពាធដ៏ធំមួយគឺលោកឧត្តមសេនីយ៍បានទុកចិត្តឲ្យខ្ញុំការពារសុវត្ថិភាពនាង!»

ឧត្តមសេនីយ៍តាមដាននាយម៉ត់ចត់ហើយ គាត់ងក់ក្បាលផ្ងក់ៗយល់សភាពការណ៍ មុនពេលលើកទូរសព្ទចុចទៅផ្ទះ។

ចិត្រានៅស្ងៀមសញ្ជឹងគិតពីអ្វីៗ ដែលខ្លួនកំពុងជួបនិងបានឆ្លងកាត់មកមួយរយៈពេលនេះ។ ត្រចៀកនាយឮសំឡេង ឧត្តមសេនីយ៍សួរនាំតាមឧបករណ៍បញ្ជូនសំឡេង៖

«រ៉ាស៊ី! កូនដាកុម្ម៉ង់ទិញអាវសមោសរមានការអី?»

នឹកឃើញពីជំទាវនោះ ចិត្រាគ្មានអារម្មណ៍អ្វីចំពោះភារកិច្ចនៅផ្ទះនោះតទៅទៀតឡើយ ប៉ុន្តែតួនាទីជាកូនចៅ ជាថ្នាក់ក្រោម ការគោរពថ្នាក់លើ គឺជាគុណធម៌ទីមួយ។

គេគិតចុះគិតឡើងម្នាក់ឯង ស្រាប់តែលោកឧត្តមសេនីយ៍ដាក់ទូរស័ព្ទចុះហើយងាកមកប្រាប់៖

«កូនស្រីខ្ញុំកុម្ម៉ង់ខោអាវ ចូលរួមពិធីរបស់ក្មួយផានូអាទិត្យក្រោយឯណោះ! រឿងជួនគ្នាទេ កុំភ័យពេក!»

ពេលឃើញចិត្រាធូរទ្រូង គាត់និយាយបន្ថែម៖

«មួយទៀត! ហើយចុះចិត្រាឯងដឹងពីណាមក ថាពួកគេសុទ្ធតែកុម្ម៉ង់ទិញខោអាវក្នុងមុនពេលបាត់ខ្លួន???»

ចិត្រានឹកដល់មិត្តដែលជាកំពូលHacker ប៉ុន្តែគេនៅតែមិនអាចនិយាយសារភាពប្រាប់ពីសមាសភាព ឯកមាន រឹតតែមិនអាចបកអាក្រាតថា ខ្លួនឯងនេះកំពុងមានគម្រោងស៊ើបក្តីក្រៅប្រព័ន្ធសមត្ថកិច្ច។ ដូច្នេះ គេនៅទីទើរមុនឆ្លើយរដាក់រដុប៖

«សុំទោសទាន! ខ្ញុំរៀនចេះHackបន្តិចបន្តួច!»

ពន្លឺភ្លឺចិញ្ចាចដោយសេចក្តីសោមនស្ស លេចចេញក្នុងកែវភ្នែកប៉ូលិសដ៏មានបទពិសោធន៍។

គាត់ងក់ក្បាលយឺតៗ ហើយក្តាប់មាត់សរសើរ៖

«ចំជាក្មួយប្រុសរបស់កំពូលប៉ូលិស!»

គេរំឭកដល់ពូរបស់ខ្លួន ចិត្រារីកថ្ពើមប៉ុនចង្អេរ។

ទឹកមុខរីករាយរបស់គេ មិនអាចលាក់កែវភ្នែកឧត្តមសេនីយ៍ឡើយ។ គាត់ញញឹមហើយលើកដៃមកកៀកកបញ្ចេញភាពជិតស្និទ្ធ។

«ខ្ញុំមិនទុកចិត្តស្នងការ Roy មួយចំណិតឯងផង វរសេនីយ៍ត្រី ជាតិ ចិត្រា!»

គេមានអារម្មណ៍ចម្លែកចំពោះភាពជិតស្និទ្ធដែលមេកោយនៅសុខៗស្រាប់តែបង្ហាញមកឲ្យខ្លួន? គេដណ្តឹងសួរខ្លួនឯង សឹងងងឹតមុខនៅតែគិតមិនយល់ពីមូលហេតុនៃពាក្យថា «ខ្ញុំដឹងថា ឯងមិនមែនជាប៉ូលិសធម្មតាទេ! ខ្ញុំផ្ញើជីវិតកូនស្រីតែមួយគត់របស់ខ្ញុំក្នុងដៃឯង ឯងគួរយល់ហើយ!»។

គេដូចជាមិនចង់លាក់ចម្ងល់យូរវែងឆ្ងាយតទៅទៀតទេ ព្រោះថានេះចំជាឱកាសដែលទំនងអាចសួរនាំដឹងរឿងបាន។ ប៉ូលិសចិត្រាផ្តើមពោលសួរមួយៗ៖

«ហេតុអ្វីខ្លះទៅដែលនាំឲ្យលោកនាយទុកចិត្តថា ខ្ញុំអាចបំពេញភារកិច្ចដ៏គ្រោះថ្នាក់នេះបានទាន?»

ឧត្តមសេនីយ៍ សើចរលាក់។ គាត់មិនព្រមផ្តល់ចម្លើយរហូតដល់ចិត្រាសួរទាំងបារម្ភ៖

«លោកនាយ! តាមការគណនា គម្លាតរវាងអ្នករងគ្រោះម្នាក់ៗមានរយៈពេល៣២ម៉ោង បើសិនជាគោលដៅរបស់ពួកវាយកអ្នកនាងអមរាជា គួរតែក្នុងល្ងាចនេះ មិនឲ្យអ្នកនាងចេញពីផ្ទះ!»

លោត ឱត សាម៉ុន រវើ្តកគិតតាមចរិតរហ័សរហួនរបស់ប៉ូលិស។

រំលឹកមកវិញ ហេតុការណ៍បាត់ខ្លួនលើកទីបួនពិតជាបានកើតឡើង កាលពីព្រហាមម្សិលបានន័យថាមកដល់ថ្ងៃត្រង់នេះមានចិរវេលាម្ភៃម៉ោងជាងហើយ។

គាត់អន្ទះសាពោលៈ

«វីវរហើយ! ថ្មើរណេះ អមរាជា មកដល់ផ្ទះហើយឬនៅទេ? ព្រោះបើប្រលងភ្លេងគួរតែចប់យូរហើយ!»

សាជាថ្មីគាត់ទូរសព្ទទៅផ្ទះ...

វគ្គ វាសនាអង្គរក្សសក្តិបួន

បរិយាកាស នៅសាលាហាត់វីយោឡុង ហាក់ស្រងេះស្រងោច ព្រោះនេះជាថ្នាក់សម្រាប់អ្នកខូចចិត្តដែលបានធ្លាក់កាលពីព្រឹក។

ផានូលើកស្មាមកបុកអមរាជាតិចៗ ហើយខ្សឹបព្រោះឃើញនាងធ្វើមុខជ្រប់ៈ

«មិនមែនចុងបញ្ចប់នៃផែនដីទេ!»

អមរាជាតបទាំងក្រញូវអន់ចិត្តៈ

«ហើយអ្នកធ្លាក់ម្នាក់ណាដែលមានអារម្មណ៍ល្អនោះ?»

ផានូធ្វើមុខហី ងាកចេញហើយឆ្លើយតបធ្វើមិនដឹងៈ

«មានអីអស្ចារ្យ? ស្មានធ្លាក់តែម្នាក់ឯង!»

អមរាជានៅតែក្តាប់មាត់មុខរំអួយៈ

«ឯងធ្វើចិត្តម៉េចបានអ្ហះ? ខ្មាសគេលាន់ហើយ នៅញញឹមស្រស់រួចទៀត!»

«គឺយើង ធ្វើកម្មដ្ឋានពត់ចិត្ត!»

កូនស្រីឧត្តមសេនីយ៍ កាន់តែងឿងឆ្ងល់លើសទុក្ខព្រួយ។ នាងសម្លក់មិត្តហើយនិយាយជជីកសួរ៖

«កម្មដ្ឋានស្អីឯងនាងនូ? ពត់ចិត្ត? ទៅកុហកក្មេងទៅ!»

ផានូមិនបានខឹងតប រឹតតែធ្វើភ្នែក ស្រស់ស្រាយហើយញញឹមម្នាក់ឯង ដូចជាស្រលាញ់បរិយាកាសជីវិតជាទីបំផុតជាមួយពាក្យរាយមាយ៖

«គឺពត់ចិត្តបានជោគជ័យ រាល់ពេលនឹកឃើញដល់ទេវបុត្រ Lorenzo របស់យើង!»

ទឹកមុខអមរាដាអៀនអន់ ពេលឮពីឈ្មោះបុរសនេះ។ ទុក្ខព្រួយហាក់រសាត់បាត់អស់ជំនួសមកវិញនូវពណ៌ក្រហមស្រៀងៗលើថ្ពាល់ទាំងសង។

«គ្រាន់តែឮអំពីគេ អៀនឡើងក្រហមមុខហើយហ្អីនាង?»

ផានូឌឺហើយពេបមាត់ដាក់កូនស្រីឧត្តមសេនីយ៍។

ដៃអមរាឈប់កេះហ្គីតា ហើយនាងងាកមកសម្លក់មិត្តវិញ។

បុរស Lorenzo ជាអ្នកណាមានតែស្រីៗប៉ុណ្ណោះ ដែលជាអ្នកច្បាស់ពីប្រវត្តិគេព្រោះជំនាញវិភាគនិងស៊ើបស្អិតដូច FBI របស់ពួកនាង។

ធម្មតាកាសែតតែងផ្សាយថា គេជាអ្នកវិនិយោគផ្នែកទេសចរដ៏អាថ៌កំបាំង សម្បូរទ្រព្យធននិងជាកំពូលអ្នកល្បីលាក់មុខ។

មនុស្សដែលប្រាកដថាបានឃើញបុគ្គលនេះ មានមិនដល់០.១ភាគរយផងទេ បើធៀបទៅនឹងពាក្យចចាមអារ៉ាម អច្ឆរិយអំពីគេដែលហោះហើរគ្រប់ច្រកល្ហកនៃព្រះរាជាណាចក្រតូចនេះ ព្រោះតែរឿងមួយគត់គឺ សកម្មភាពមនុស្សធម៌ដ៏រំជួយមេឃដែលព័ត៌មានបានចេញផ្សាយពីការបរិច្ចាគ ប្រាក់មួយលើក ជាពីរលើក ក្នុងទំហំធំច្រើនរហូតដល់សេដ្ឋីផ្សេងនានាចំហមាត់។

«អៀនស្អីទៅ? យើងឯណាដែលបានឃើញគេ រកលង់ស្អីរួចលង់តាមណា? មិនដូចឯងទេ គេងស្រមៃ តាមសប្បាយ ស្រមៃដល់ចាស់ទៀត ក៏យើងមិនឃាត់ដែរ កុំតែទាញយើងទៅ

តាមបានហើយ! ថ្ងៃនេះស៊យគ្រប់ហើយ! ហ៊ឺះ! និយាយទៅ មកពីប៉ិអង្គរក្សហ្នឹងទាំងអស់! យ៉ាប់ម៉ង! នាំរឿងយ៉ាប់មកទាំងព្រលឹម?»

ផានូញាក់ចិញ្ចើមស៊ីញ៉ូ នាងឈប់និយាយហើយឲ្យងាកទៅមើលទ្វារបន្ទប់ ឯខាងស្ដាំដៃ។

អមរាដាក៏ងឿងឆ្ងល់ ហើយងាកទៅមើលតាមការចង្អុលរបស់មិត្ត។ កូនស្រីឧត្ដមសេនីយ៍ចាប់ផ្ដើមបើកភ្នែកធំៗ ព្រោះនាយជាតិ ចិត្រាពិតជាកំពុងមានវត្តមាននៅក្លោងទ្វារ។

បុរសសក្តិបួននេះ ស្រាប់តែនឹកដើមដង្ហើមដល់ជាមួយឯកសណ្ឋានទីនុយសឹងផ្អើលមេឃ។

អស់ពីស្រលាំងកាំង ស្រីស្អាតចាប់ផ្ដើមកើតអារម្មណ៍តប់ប្រមល់។ ការដែលមានអង្គរក្សហែតាមរហូតដល់សាលារៀន ជារឿងគួរឲ្យឈឺចាប់ស្រាប់ហើយ មកបន្ថែមទម្ងន់ ដែលនាយនេះហ៊ានផ្លោយចូលក្នុងបន្ទប់ រុករើសម្ភារនាងមិនទាន់បាត់ក្ដៅផង ឲ្យស្រីស្អាតនៅស្ងប់កើតដែរ?

ពេលនេះគេមិនត្រឹមមើលឃើញនាង ថែមទាំងបង្ហាញខ្លួនឈរទ្រឹងក្បែរបង្អួច គ្មានសូម្បីតែក្រែងចិត្តគ្រូបង្រៀក។

«អ្ហើយ! ហើយពីណាប្រើអង្គរក្សយ៉ាប់ម្នាក់ហ្នឹងឲ្យមកដល់កន្លែងយើង!»

នាងខ្សឹបតិចៗ ទាំងសៅហ្មងចំណែកផានូតបរិញ្ញទាំងអស់សំណើចៈ

« ប៉ាឯងហ្នឹង! គ្រាន់បើទៅថាឱ្យគាត់ទៅនាង»

មិនទាន់ផុតពីមាត់ស្រួលបួល ទូរស័ព្ទនាងរោទ៍។

លេខប៉ានាងធ្វើឲ្យនាងចង់យំក៏យំមិនចេញ។ ផានូកាន់តែបានចិត្តចំអកឲ្យមិត្តៈ

«ថាអីខុស!»

អមរាដាមិនរវល់នឹងសម្ដីស៊កសៀតរបស់ផានូឡើយ នាងលើកទទួលទូរស័ព្ទឈ្មម ពេលគ្រប់គ្នាងាកទៅ មើលនាយសក្តិបួនដែលឈរក្រៅទ្វារ។

តឹងទ្រូង… ពិតជាកំពូលតឹងទ្រូង… ស្រីស្អាតខាំមាត់ស្ទើរដាច់ ហើយបន្ទរសំឡេងឲ្យទាបបំផុតខ្សឹបទៅកាន់លោកឪពុកៈ

«ប៉ាអើយ!!!?… ប៉ាបញ្ជូនម្នាក់ហ្នឹងមកធ្វើអី?»

«ម្នាក់ណា?»

«ប៉ូលិសស្អីគេហ្នឹង!»

«ក្រែងកូនឯងកូនប៉ូលិស?»

«អ្ហូយកូនចងនិយាយថា ប៉ូលិសម៉ាស្រុកខ្មែរ មិនរំខានស្មើម្នាក់ស័ក្តិបួនរបស់ប៉ាឯងហ្នឹងផង!»

ឧត្តមសេនីយ៍សើចរលាក់មុនពេលឆ្លើយ៖

«គេទៅការពារកូនឯង!»

ឧត្តមសេនីយ៍ឆ្លើយខ្លី តែក្នុងន័យមិនលេងធេង ធ្វើឲ្យនាងធ្វើមុខជូរ ដូចត្រូវនឹងក្តឹបស្វាយ។ អមរាជាអស់ពីហួសចិត្តដែលឪពុកមានរឿងប៉ុនណា នៅតែមិនចោលនាយអង្គរក្សចំណាប់នេះ។ ស្រីស្អាត រំអួយផងខ្សឹបផងទាំងកន្ទុយភ្នែកវាត់ទៅរកនាយអង្គរក្ស៖

«អ្នកណាថាកូនត្រូវការ??? គេនេះគ្មានបានការអីក្រៅពីនាំក្តៅក្រហាយហ្នឹង! ឲ្យគេទៅវិញភ្លាមទៅ! ទៅឲ្យឆ្ងាយៗពីកូន ក្រែងអ្នកម៉ាក់ឲ្យគេឈប់ហើយហ្អី?»

លោកឧត្តមសេនីយ៍ពោលតបមកវិញមធ្យ័ត៖

«ស្តាប់ប៉ា! ហាមទៅណាឆ្ងាយពីគេ សូម្បីតែមួយជំហាន! សុវត្ថិភាពកូនកំពុងត្រូវគំរាម!»

នាងចងចិញ្ចើម និមិត្ត តែឮពាក្យចុងក្រោយហើយចាប់ផ្តើមល្ងើងទឹកមាត់ជាមួយឃ្លា។ «សុវត្ថិភាពកូនកំពុងត្រូវគំរាម»។

ខ្លួនជាកូនប៉ូលិសស្រាប់ នាងយល់ច្បាស់ណាស់ពីពាក្យអស់នេះ ហើយរឹតតែច្បាស់ទៅទៀតដែលថាលោកប៉ាមិនដែលយករឿងសុវត្ថិភាពមកគំរាមលេងសើចទេ។

នារីដៀងភ្នែកមករកមិត្ត ហើយរយើតៗលបសម្លឹងប្រតិកម្មមនុស្សម្នារួមថ្នាក់ភ្លេង ដែលកំពុងមើលទៅបុរសនៅក្បែរបង្អួចហាក់ដូចជាផ្ទាំងស៊ីប។

បើគេដឹងថា បុរសឈរវត្តុបដូចមនុស្សយន្តនេះជាអ្នកការពារ នាងច្បាស់ក្លាយជាប្រធានបទឲ្យគេនិយាយគ្នាសើចពេញទីនេះមិនខាន ។

ស្រីស្អាតគិតឃើញកាលណា អារម្មណ៍ច្រាស់ច្រាល់ មិនអាចថាទប់ចិត្ត មិនតបតនឹងឪពុកបាននោះទេ នាងខ្សឹបទាំងខាំមាត់៖

«ប៉ាអើយ!... នៅនេះ គ្មានអ្នកណាគេយកអង្គរក្ស ចូលមកដល់កន្លែងរៀនទេប៉ា!»

ឧត្តមសេនីយ៍ ឌិត សាម៉ុន ពន្យល់វិញ៖

«កូនដា! កូនស្រីគេបាត់ខ្លួនអស់បួននាក់ហើយ! ប៉ាមិនអាចបណ្តោយទេ! អ្នកណាថាអីក៏ដោយមិនឲ្យសក្តិបួននេះឃ្លាតពីខ្លួនមួយជំហាន! ធ្វើតាមប៉ា!»

ភាគទី៨

នារីដាក់ទូរសព្ទចុះទាំងចិត្តមួហ្មង។

នៅក្បែរបង្អួច ចិត្រាឈរផ្ទុប បំពេញកាតព្វកិច្ចជាកងការពារគ្រប់ជំហាន ដូចរូបចម្លាក់មិននិយាយមិនស្តី ធ្វើឲ្យស្រីស្អាត ក្រឡេកទៅឃើញគេកាលណា រឹតតែទើសទាល់ចិត្ត។

បុរសនេះមិនបានខ្វល់ខ្វាយពីអ្វីដែលស្រីៗខាងក្នុងកំពុងសៅហ្មងទេ ចិត្តផ្តោតតែលើការបារម្ភពីព័ត៌មានបាត់ខ្លួនស្រីក្រមុំត្រកូលអភិជន។

គេដឹងថា ករណីដែលកំពុងល្បីកក្រើក គំរាមពាសពេញទីក្រុង នៅតែមិនទាន់មានឥទ្ធិពលធ្វើឲ្យធីតាកូនអ្នកមាន អំណាចម្នាក់នេះគិតថាជាសភាពការណ៍ធ្ងន់ធ្ងរដូចដែលឪពុកនាងកំពុងព្រួយនៅឡើយ ព្រោះនាងមិនទាន់បានឃើញផ្ទាល់ភ្នែក។ ប៉ុន្តែប្រសិនទម្រាំរង់ចាំ ដល់នាងជួបជនដៃដល់ផ្ទាល់ភ្នែក អ្នកណាអាចជួយនាងបាន?

គេគិតហើយភ្នែករំពៃពិនិត្យគ្រប់សភាពការណ៍មិនហ៊ានប្រហែស។

«អ្នកណាទៅជាអ្នករងគ្រោះទី៥?»

ឆាតរបស់ឯកមាន លោតមកសួរ ចំណែកអង្គរក្សឯណោះ រកចម្លើយឯណាតបបាន បើនៅជាប់កាតព្វកិច្ចយាមកាមកូនស្រីលោកធំមិនស្ទើរមិនហ៊ានសូម្បីតែប៉ប្រិចភ្នែកផង?

«ប្អូនខាងណោះចូលរៀនដែរអី?»

គ្រូបង្វឹកសួរ ធ្វើឲ្យគ្រប់គ្នាតម្រង់ខ្សែភ្នែកទៅរកបង្អួចសាជាថ្មី។

«អង្គរក្សផ្ទាល់ខ្លួន! ជាអង្គរក្សទេបាទ!»

គេឆ្លើយទាំងឈរត្រង់ខ្លួនដូចមនុស្សយន្ត ធ្វើឲ្យស្រីស្អាតខ្មាសសឹងថា ងើបមុខមិនរួចពីឧបករណ៍ភ្លេង។ ទោះបីគ្មានអ្នកណាទាន់និយាយថាបុរសនេះមកឈរត្រេងត្រាងការពារនាង តែចិត្តកូនឧត្តមសេនីយ៍ដឹងច្បាស់ហើយថាអាវប៉ូលិសរបស់គេជាតឹកតាងមិនបាច់ចាំបកស្រាយ។

គ្រូភ្លេងញញឹម និយាយតបៈ

«អត់អីទេ! បងដឹងមួយរយៈនេះភ្នំពេញមានរឿងអសន្តិសុខច្រើន! តែ ម៉េចក៏មិនរកកន្លែងអង្គុយ ម៉ោងរៀននៅវែងទៀតណា!»

ដឹងអីជាការឆ្លើយតបនឹងសម្ដីគួរសមនៃគ្រូបង្វឹក បុរសអ្នកការពារបែរជារក្សាឥរិយាបថឆ្អឹតដូចមនុស្សយន្តៈ

«វិន័យសម្រាប់អង្គរក្ស មិនអាចអង្គុយពេលបំពេញការងារទេបាទ!»

អមរាដាក្ដាប់មាត់សៅហ្មង ព្រោះនឹកថានេះជាចរិតឃ្លើនរបស់គេ។ ចំណែកគ្រូបង្វឹកទៅជាចំហមាត់ពេលឮចម្លើយគេ។ គាត់ងៀងភ្នែកមកមើលស្រីស្អាត។ ខ្សែភ្នែកគ្រូបង្វឹក ទំនងដឹងជាស្រេចថា នារីនេះតែម្ដងដែលជាចៅហ្វាយរបស់បុរសឈរឆ្អឹងនៅក្រៅបង្អួច គ្រាន់តែគាត់មិននិយាយចេញមក។ ពេលលបមើលអមរាដា ឃើញមិត្តកំពុងខឹងក្នាញ់អង្គរក្សសក្ដិបួនខ្លាំងឡើងៗតាមរយៈទឹកមុខ។ ចំណែកសិស្សផ្សេងៗក៏ឈប់លេងភ្លេងអស់នាំគ្នាខ្ទប់មាត់តាមមើលសកម្មភាពអង្គរក្សចម្លែក។ ដើម្បីសម្រួលស្ថានការណ៍ គ្រូបង្វឹកនិយាយបន្ថែមៈ

«អូខេ! អាចថា ប្អូនរកកន្លែងដែលអាចសមគួរជាងនេះក៏បាន! ឬមួយ អាចអ៊ីចេះទេ! ចូលមកក្នុងសាលមក កុំនៅក្បែរបង្អួច!»

ពួកអ្នកដែលស្ដាប់ឮ ចាប់ផ្ដើមសើចគិលឡើង ធ្វើឲ្យអមរាដាកាន់តែក្ដៅស្លឹកត្រចៀក។ បន្ថែមលើភ្លើង នាយអង្គរក្សឆ្លើយតបបែប «មិនខ្វីខ្វល់» ទៀតៈ

«ភារៈជាអង្គរក្ស ចៅហ្វាយនៅត្រង់ណា ត្រូវនៅត្រង់ណោះ! ពេលឈរការពារ មិនឲ្យឈរពីមុខ មិនឲ្យនៅពីក្រោយ មិនឲ្យនៅចំហៀងកៀកជាងមួយម៉ែត្រ!»

អមរាដានិយាយកាត់ខ្សោយៗតែទាំងកំហឹង៖

«មកអង្គុយលើក្បាលខ្ញុំម៉ងក៏បាន!»

ថាចប់ នាងបែរទៅសម្លក់នាយមួយទំហឹង ធ្វើឲ្យបុរសអ្នកការពារស្លុតស្មារតីនឹងសម្រស់ដ៏ផូរផង់ពេលថ្ពាល់នឹងភ្នែកទាំងគូរបស់នាងប្រែទៅជាក្រហមឆៅ។

ផានូធ្វើមុខភ្លឹះៗ ព្រោះស្ថានការណ៍នៅសុខៗ តឹងតែងជាងព័ត៌មានបាត់ខ្លួនស្រីស្អាតៗទៅទៀត។ នាងលើកដៃអង្អែលមិត្តសម្រន់កំហឹង តែចិត្តក៏នឹកឃើញពីសម្ដីទូន្មានកាលពីព្រឹករបស់នាយ Roy ដែលនាងទៅដល់ទាន់ ហើយស្ដាប់ឮគួរឲ្យទើសត្រចៀក។

ទោះបីជាក្នុងចិត្តចិត្រាដឹងថានឹងត្រូវថ្នាំងរបស់នារីនេះ បន្ថែមពីលើរឿងព្រឹកមិញ តែនាយនៅឈរបំពេញការងារ មិនខ្វីខ្វល់ថាអ្នកណាគិតយ៉ាងណាទាំងអស់ ព្រោះជាបទបញ្ជាដែលជៀសមិនរួច។

គ្រូបង្វឹកលែងចេញស្ដី ព្រោះបរិយាកាសទំនងហួសពីសមត្ថភាពរបស់គាត់ ក៏ងាកទៅចាប់ឧបករណ៍ភ្លេងហើយលេងបង្ហាញជាបន្ត។

«បើយើងស្លាប់គឺមកតែពីរអាគាត់នេះ!»

នាងរអ៊ូតិចៗ ពេលផានូឱនមកលួង។

សម្ដីអមរាដាក្រៅពីធ្វើឲ្យផានូអស់សំណើច ថែមទាំងជំរុញឲ្យនាងហួសចិត្តមិនអាចអត់ទ្រាំមិនងាកមកមើលបុរសអង្គរក្សបាន។ បុរសនេះពិតជាសង្ហាហើយមាំទាំ អង់អាច ទាស់តែចរិតគេរឹងហួសហេតុដូចមនុស្សយន្ត មិនស្គាល់ខុសត្រូវ តើគួរនិយាយថាអមរាដាខឹងត្រូវ ឬក៏បុរសនេះបំពេញការងារត្រឹមត្រូវ។

នាងដកដង្ហើមធំហើយងាកមកខ្សឹបនឹងមិត្ត៖

«ឯងមិនអាចនិយាយគេពីរឿងឈរបាន តែឯងអាចប្រើគេបាន!»

«ប្រើធ្វើស្អី? មនុស្សដូចគេនេះ ធ្វើស្អីបានទៅអ្ហះ?»

នាងខ្សឹបសួរវិញទាំងចិត្តក្ដៅឆេវ។ ផានូញញឹមហើយបង្គាប់៖

«ប្រើអីក៏ប្រើទៅ ប្រើយ៉ាងណាឲ្យគេទៅឲ្យបាត់ៗសិនទៅ!»

អមរាជានៅស្ងាត់ស្ងៀមបង្ហាញថា នាងគ្មានផ្លូវព្រមនិយាយរកនាយអង្គរក្សឡើយ ធ្វើឲ្យស្រីស្អាតជាមិត្តយល់ចិត្ត ងាកទៅបង្គាប់ជំនួសតិចៗ៖

«បង! បង!»

ផានូហៅពីរដងទើបគេងាកមក។

«អមរាជាប្រើឲ្យបងឯងជួយទៅទិញទឹក! ហើយ ហើយទៅយកថ្នាំផ្តាសាយក្នុងឡានរបស់គាត់ផង បានអត់?»

គេសម្លឹងផានូ ហើយមើលហួសទៅកាន់ស្រីស្អាតជាកូនលោកឧត្តមសេនីយ៍។ អ្នកនាងធំពិតជាស្អាតពេកហើយ ជាមួយថ្ពាល់ក្រហមរបស់នាង។ គេបែរជាមិនគិតថានាងខឹង តែគិតថានាងកើតផ្តាសាយត្រូវការថ្នាំពិត មែន។

ចិត្តនាយអន្ទះសាស្ម័គ្របម្រើស្រីស្អាត បានជាដាច់ចិត្តចោលកាតព្វកិច្ច យាមកាមហើយចាប់សោឡានដែលផានូបោះមកឲ្យ ដើរទៅរកថ្នាំតាមពាក្យបង្គាប់។

«ឃើញអត់? ធូរទ្រូងមួយគ្រាហើយ!»

ផានូនិយាយទៅកាន់មិត្តទាំងញាក់ចិញ្ចើមផង។ ប៉ុន្តែអមរាជានៅតែមិនបញ្ចេញអាការសប្បាយអ្វីជាដុំកំភួនឡើយ។ នាងនិយាយតបវិញទៅកាន់ផានូ៖

«ក្នុងឡានគ្មានថ្នាំទេ ទឹកក៏អត់ដែរ!»

ផានូសើចខឹកហើយនិយាយតបវិញ៖

«ឲ្យគេរកតាមដំណើរទៅអ៊ីចឹង!»

វគ្គ តម្រុយពីរចំណុចរបស់ឯកមាន

យប់ដដែល...

«ម៉េចហើយអ្នំា អាអង្គរក្សកម្សត់?»

ឯកមានសួរផង ហូបម្ហូបឆាឃ្មមៗយ៉ាងមានក្តីសុខ។ ចិត្តអង្គរក្សពេលនេះ នៅតែផ្តោតលើរឿងមួយចំនួនស្រាយមិនចេញ ទោះបីជាគេមកដល់ផ្ទះម៉ោង៩យប់ត្រឹមទៅហើយ នៅតែមិននឹកឃើញឃ្លានបាយទឹក។

«ម៉ាក់និងអាមាន ចាំកូនឯងយូរពេកបានជា ចាប់ផ្តើមញ៉ាំបណ្តើរៗទៅ ការងារអីយប់ម៉េះកូន? ទូរស័ព្ទក៏ខលទៅមិនឃើញលើក! ម៉ោះ! ញ៉ាំជាមួយគ្នាម៉ងឬម៉េច?»

ចិត្រាដោះអាវឯកសណ្ឋានទៅព្យួរ ហើយដៃរាវរកទូរសព្ទមាត់ឆ្លើយតបនឹងម្តាយ៖

«ពេលបំពេញការងារជាអង្គរក្ស កូនមិនចង់និយាយទូរស័ព្ទ បានជាបិទសំឡេងចោល! កូនស្រីមេទើបតែចូលផ្ទះមិញនេះ!»

បុរសទាញកៅអីអង្គុយរួមតុ។

ឯកមាននិយាយផងខ្ចីផង៖

«ចៅហ្វាយស្រីឲ្យតាមយូរកន្ទ្រកដល់ណាខ្លះអាចៅចិត្ត?»

«ទៅហាត់ភ្លេង! ហាត់ប្រាណ! ហើយចុងក្រោយដើរទិញអីវ៉ាន់! គេមានកន្ត្រករុញហើយចាំបាច់អីយួរ?»

ឯកមានសើចក្អាកក្អាយ៖

«ចង់ឃើញរាងឯងពេលរុញកន្ត្រក!»

ម្តាយសម្លឹងមុខកូនភ្លឹះៗ ព្រោះសេចក្តីអាណិតស្រលាញ់ ប៉ុន្តែជាតិចិត្រា មិនបានបង្ហាញត្រង់ណាដែលថាខ្លួនតូចចិត្តទោមនស្សនឹងការងារថ្ងៃនេះសោះ។

«ម៉េចហើយកូន ការងារហត់ពេកឬអី?»

ទើបនឹងចាប់អារម្មណ៍ថាម្តាយបារម្ភ។ នាយសក្តិប្អូន ញញឹមហើយបន្ទន់ចិត្តគាត់៖

«មានហ្ន៎ម៉ាក់! អាមានវាច្រណែនដែលមិនបានដើរត្រសងមួយស្រីស្អាតៗដូចកូន! ម៉ាក់កុំទៅស្តាប់សម្តីចាក់ដោតរបស់វា! កូនមិនអីទេការងារប៉ុណ្ណេះ!»

គេចាប់ផ្តើមដួសអាហារដាក់មាត់ ម្តាយក៏ធូរទ្រូង។

«ញ៉ាំទៅកូន ម៉ាក់ទៅចិត្តផ្លែឈើមកឲ្យញ៉ាំ!»

ម្ដាយក្រោកភ្លែត នាយឱនភ្លឹបមកខ្សឹបឯកមាន៖

«ម៉េចក៏៣២ម៉ោងផុតហើយ គ្មានព័ត៌មានអ្នករងគ្រោះទី៥អ្ហ៎ា?»

ឯកមាន នៅទ្រឹងលែងទំពា ហើយកែវភ្នែកក្រឡេក គិតចុះឡើងយ៉ាងរហ័ស។ គេមិនទាន់និយាយអ្វីតែទឹកមុខគេដូចជាបញ្ជាក់ស្រេចហើយនូវសំណួរតឹងតែងថា៖

«ដល់ហើយ៣២ម៉ោងទៀតហើយអ្វី?»

«អើ! អ្ហែងមិនរាប់? ឬកអ៊ីចឹងចង់ស៊ើបក្ដីផង អាចោរ!»

ឯកមានលើកទឹកក្រេប។ ជាមួយនឹងភាពស្ងាត់ស្ងៀមរបស់គេ ចិត្រាថាឲ្យបន្ថែមទាំងមាត់នៅទំពាបាយញ៉ាច់ៗ៖

«ម៉េចក៏សភាពការណ៍ស្ងាត់ល្អមម៉េះអ្ហ៎ា?»

«អញម៉េចដឹង? អ្ហែងសួរច្រើនម្ល៉ឹងៗ មើលតែអញស្គាល់វា ដឹងចិត្តវា!»

ឯកមាន ថយទៅរកសាឡុង ហើយបើកសាក់កាដូ ទាញកុំព្យូទ័រមក។ ម្រាមគេចុចញាប់ស្មេរពេលដែលចិត្រាក៏ថយទៅបើកទូរទស្សន៍។

«អ្ហែងជឿរឿងមន្តអាគម អូមអាម អត់អ្ហ៎ាអាមាន?»

Hacker រវល់នឹងការងារ លើកុំព្យូទ័ររបស់គេ រហូតដល់គ្មានពេលតប។ មិនខ្វល់ថា គេកំពុងរុករកអ្វី ចិត្រាថយមកក្បែរមិត្តជាមួយនឹងឧបករណ៍បញ្ជាទូរទស្សន៍នៅជាប់នឹងដៃ ហើយចាក់ឃ្លាសន្ទនាបន្ថែម៖

«ព្រឹកមិញដែលគាត់ខលហៅអញទៅ គាត់នាំអញទៅជួបគ្រូអូមអាមម្នាក់!»

ឯកមានឈប់ដៃហើយជ្រួញចិញ្ចើម ហើយងើបមុខមកសម្លឹងមិត្ត។ ទោះមាត់គេមិនទាន់បញ្ចេញសំណួរ ប៉ុន្តែចិត្រានិយាយបន្ថែម៖

«អ៊ំនោះនិយាយថា តាមជំនឿពួកអ្នករៀនវិជ្ជាអាគមងងឹត គេអាចប្រើមនុស្សស្រីពេញវ័យកើតឆ្នាំរោង៣៥នាក់ដើម្បី រួមគ្នាមកកែប្រែជោគវាសនាឲ្យអ្នកណាម្នាក់ ក្លាយទៅជាអ្នកមានអំណាចផុតកាលបាន!»

ដូចគ្នាកាលចិត្រាស្ដាប់សម្ដីនេះពីមាត់បុរសនៅតំបន់ក្រីក្រនោះដំបូងដែរ ឯកមានបង្ហាញទឹកមុខបើកចំហជាសញ្ញាថា គេស្ដាប់មិនយល់អ្វីដែលវរសេនីយ៍ត្រីព្យាយាមប្រាប់នេះសោះ។ សម្ដីអស់នេះ កុំថាឡើយធ្វើឲ្យអ្នកវិទ្យាសាស្ត្រកុំព្យូទ័រដូចឯកមានត្រូវចំហមាត់ សូម្បីយកទៅនិយាយដាក់ក្មេង៧ឆ្នាំក៏ត្រូវគេដៀលថាឆ្កួតដែរ។

ដឹងអីចឹងហើយចិត្រានៅតែនិយាយបន្ថែមឲ្យចប់ចុងចប់ដើម៖

«អ្ហែងដឹងគាត់និយាយថាម៉េចអត់? គាត់ថា ចំនួន៣៥គឺជាការគុណ៧ដង នៅជ្រុងតូចៗរបស់ពួកផ្កាយ អ្នកភូគព្ភសាស្ត្រជឿថា នេះគឺជាចំនួនខ្ពស់បង្អស់នៃក្បួនកែប្រែថាមពលរបស់ភពផែនដី!»

ឯកមានសម្លឹងមុខចិត្តយូរៗក៏ផ្ទុះសំណើចសើចខឹកៗ បន្ទរពីក្រោយទឹកមុខមឹងម៉ាំងរបស់ជាតិចិត្រាធ្វើឲ្យវរសេនីយ៍ត្រីរូបនេះ រឹតតែមានអារម្មណ៍អៀនខ្មាសហាក់បីដូចជាខ្លួនកំពុងត្រូវបានគេចាត់ទុកថាជាតួកំប្លែង។

ម្ដាយលើកថាសបង្អែមមកដល់ នាយក្រោកទៅចាប់ចំណិតផ្លែប៉ោមមកខាំបន្លប់ ជាមួយពាក្យឡុលៗ៖

«អ្ហែងសើចអញស្អី? ស្មានថាអញស្ដាប់តានោះហើយ យល់បានម៉ាចំណិតណាអ្ហី?»

ឯកមានឈប់សើចហើយតបត៖

«អញមិនបានសើចឯង តែអញសើចដែលឧត្តមសេនីយ៍មួយទាំងមូល នាំឯងទៅជួបពួកអ្នកបោកអស់ហ្នឹង!»

ម្ដាយចិត្រាអង្គុយយឺតៗ ក្បែរឯកមាន ហើយវាចាកាត់មួយៗ៖

«កុំសើចលេងកូន! ស្រុកខ្មែរយើងក្នុងចំណោមមនុស្ស១០នាក់ មាន៩នាក់ហើយដែលជឿលើរឿងអ៊ីចឹងៗ!»

«តែឧត្តមសេនីយ៍ ឱត សាម៉ុន គួរតែគ្មានក្នុងចំណោម៩នាក់នោះទេមីង!»

គេងាកមករកចិត្រាហើយនិយាយបន្ថែម៖

«ស្ដាប់អញអាចិត្រ! តាហ្នឹងរកតម្រុយមិនឃើញ ធ្លាក់ខ្លួនដល់ថ្នាក់ទៅរកគ្រូទាយ វាជាឱកាសសម្រាប់ក្មេងៗជំនាន់យើងយកលុយរង្វាន់ការប្រពន្ធម្ដងហើយ!»

ចិត្រាលើកដៃច្បូតមុខហើយអង្គុយមកក្បែរម្ដាយដែរ។ ចិត្តនាយខ្វល់ខ្វាយគិតដល់រឿងជាច្រើន ជាមួយគ្នានោះ សម្ដីឧត្តមសេនីយ៍នៅតែលាន់មកក្នុងការចងចាំ «ឯងចង់ចូលរួមជាមួយខ្ញុំបំបែកសំណុំរឿងនេះទេ?»។

គិតឃើញដល់បុរសនោះ គិតឃើញដល់ការទុកចិត្តនិងកម្លាំងចិត្ត ភាពស្និទ្ធស្នាល ដែលគាត់ផ្ដល់មកឲ្យអារម្មណ៍កក់ក្ដៅ និងសេចក្ដីក្លាហានហាក់កើតមានរសឹបពេញរាងកាយ។ គេដៀងមករកមិត្តដែលអស់ពីសើចកក្អឹក ពេលនេះឯកមានកំពុងជក់ចិត្តលើអ្វីម្យ៉ាងលើកុំព្យូទ័ររបស់គេ។

ចិត្រាស្ទុះទៅកៀកក្បែរមិត្តហើយខ្សឹបសួរ៖

«នែ៎! ព្រឹកមិញអ្ហែងមិនទាន់និយាយអាពីរចំណុចទៀតប្រាប់ផង គាត់ក៏ខលមកហៅអញចេញទៅ!»

ឯកមាន ងាកមកមកវិញហាក់មមីងឿងឆ្ងល់ហើយសួរបក៖

«អញមិនទាន់បាននិយាយទេ??!»

«នៅ! និយាយពីអង្កាល់? អ្វះ? ស្អីខ្លះ? ឯងរកឃើញស្អីខ្លះ?»

ឯកមាន បែរមករកវរសេនីយ៍ត្រីដែលកំពុងរង់ចាំស្ដាប់។ ជាមួយទឹកមុខមធ្យ័ត Hacker សក្តិប្អូននិយាយពន្យល់មួយៗក្នុងសំឡេងទាប ល្មមឮតែពីរនាក់៖

«កំណត់ត្រាត្រូវលុបបាត់ភ្លាម ក្រោយពេលអញឃើញពួកគេបានកុម្ម៉ង់ខោអាវក្នុង!»

ចិត្រាជ្រួញចិញ្ចើម៖

«បានន័យថាម៉េច? អ្នែងឆែកឃើញហើយ ក៏ត្រឡប់ទៅវិញម្ដងទៀតលែងបាន ទិន្នន័យត្រូវលុបបាត់?»

ឯកមានងក់ក្បាលផ្ងក់ៗ ធ្វើឲ្យចិត្រាផ្ទង់អារម្មណ៍ពិចារណាទាំងមិនអស់ចិត្ត។ មាត់នាយរអ៊ូចុះឡើងៗ៖

«អស្ចារ្យម៉េះអ្ហា?»

«គ្មានអីអស្ចារ្យទេ! គ្រាន់តែវិជ្ជាគុណលេខកូដផុនវាខ្លាំងជាងយើងមួយកម្រិត!»

ឯកមានឆ្លើយធ្វើវាហី ទោះបីទទួលស្គាល់ថាខ្លួននៅចាញ់ជនអនាមិកនោះមួយជំហានទៅហើយក្ដី។

ដែលមិនអស់ចិត្តជាងគេក្នុងបន្ទប់នេះគឺ ចិត្រា។ ចំណោទផ្ទួនៗគ្មានចម្លើយ តើឲ្យនាយយប់នេះសំងំគេងលក់យកកម្លាំងបម្រើលោកឧត្តមសេនីយ៍កើតដែរ?

«វាជាអ្នកណា? ហើយវាធ្វើអ៊ីចឹងធ្វើអី?»

ឯកមាននៅស្ងៀម រឹតតែបង្កឱកាសឲ្យនាយសក្តិបួនជាមិត្តខ្លួន សន្និដ្ឋានចុះឡើងៗមិនល្ហែ៖

«បើវាចង់លុបកំណត់ត្រា Internet ហេតុអីចាំដល់ឯងឃើញហើយបានវាមកលុបតាមក្រោយ?»

មិនឃើញឯកមាន មានប្រតិកម្ម វរសេនីយ៍ត្រីនិយាយបន្ថែមទៀតតាមសន្ទុះចិត្តពុះកញ្ជ្រោល៖

«អាណាម្នាក់កំពុងតែលេងបិទពួន! ការចាប់ខ្លួនស្រីៗអាចជាហ្គេមម្យ៉ាងរបស់វាសំដៅមកប៉ូលិស!»

«ហើយចំណុចទីបី គឺអញដឹងថា អាណានៅពីក្រោយហ្គេមហ្នឹង!»

ឯកមាន និយាយទាំងញញឹមបញ្ចេញស្នាមអំនួតលើថ្ពាល់ម្ខាង។

ចិត្រាងាកទៅរកមិត្ត ហើយសម្លឹងទៅអ្វីម្យ៉ាងលើអេក្រង់កុំព្យូទ័ររបស់ ឯកមាន។

«ធៀបស្អីគេ? របស់អ្នកណា? ម៉េចអញដូចធ្លាប់ឃើញ???»

គេភ្លាត់មាត់សួរតិចៗទៅតាមសេចក្ដីសង្ស័យនឹងភ្ញាក់ផ្អើល...

វគ្គ រាត្រីសមោសរ ពណ៌ព្រះចន្ទ

សាជាថ្មី ឯកមានឧុបចិត្រាសំដៅទៅផ្ទះលោកឧត្តមសេនីយ៍ទាំងយប់។ ដោយសារការទាក់ទងគ្នាមុន ពូហឿនក៏បានចេញមកចាំទទួលប៉ូលិសទាំងពីរដល់មាត់ទ្វារ។ រីឯឯកមានថយទៅរង់ចាំនៅស្ដាម៉ាតកាច់ជ្រុងដើមផ្លូវជាមួយកុំព្យូទ័រចល័តរបស់គេ។

«លោកឧត្តមសេនីយ៍ចាំនៅខាងលើ!»

ចិត្រាត្រូវបានអនុញ្ញាតឲ្យឡើងទៅជួបលោកដល់ជាន់ខាងលើ ហើយឃើញបុរសចំណាស់កំពុងស្ថិតក្នុងសម្លៀកបំពាក់ហាត់ប្រាណ ទឹកមុខពេញដោយចម្ងល់ ពេលឃើញភាពត្រហេបត្រហបរបស់យុវជនជាមួយវគ្គមានកណ្ដាលរាត្រី។

«មានការអី ប្រញាប់ដល់ថ្នាក់ជួបគ្នានៅស្អែកការស្អែកមិនបាន!?»

ទោះយ៉ាងណាទឹកមុខបុរសពេញដោយពិសោធន៍ជានាយប៉ូលិសជើងចាស់ មិនបានបង្ហាញអ្វីដែលថាគួរឲ្យរងរំខានឡើយ នេះជាប្រការលើកទឹកចិត្តឲ្យជាតិ ចិត្រា ប្រញាប់ដាក់ពាក្យស្នើសុំបន្ទាន់៖

«សូមលោកនាយអនុញ្ញាតឲ្យខ្ញុំបានបើកពិនិត្យឡានរបស់អ្នកនាងអមរាជា! ខ្ញុំសង្ស័យថាអ្នកនាងបានទទួលលិខិតអញ្ជើញកម្មវិធីចម្លែកមួយ ដែលអ្នកបាត់ខ្លួនបួននាក់មុនៗបានទទួលដូចគ្នា មុនពេលគេតែងខ្លួនចេញពីផ្ទះ!»

ភាគទី៩

លោក ឱត សាម៉ុន បញ្ចេញសេចក្ដីសង្ស័យ ពេលសម្លឹងមករកនាយសក្តិបួន។

ភាពត្រហេបត្រហបរបស់គេនាពេលយប់អាធ្រាត្រកាន់តែបង្ខំធ្វើឲ្យគាត់សង្កត់ចិត្ត អត់ធ្មត់ រង់ចាំស្ដាប់ បន្តឲ្យបានចប់ចុងចប់ដើម ដើម្បីនឹងយល់ដល់សេចក្ដីដែលនាយកំពុងចង់ពន្យល់។

«ជម្រាបប្រសាសន៍ទាន! មានលិខិតអញ្ជើញចូលរួមកម្មវិធីចម្លែកមួយ ដែលអ្នកបាត់ខ្លួនទាំងបួន បានទទួលដូចគ្នា!»

ឧត្តមសេនីយ៍ដៀងមកមើលក្រដាសដែលPrint ចេញហើយជាស្រេច លើដៃនាយប៉ូលិសវ័យក្មេង។ គាត់ឃើញពាក្យថា «រាត្រីសមោសរពណ៌ព្រះចន្ទ» ចិញ្ចើមជ្រួញឆ្ងល់តែដៃនៅមិនទាន់លូកទៅយកមកពិនិត្យព្រោះរវល់សួរនាំ៖

«មានទាក់ទងអីជាមួយឡានកូនដា?»